(២៩)

# សំណើប្រគល់មុខងារជាអាណាប័កផ្ទេរសិទ្ធិ
# ជូនប្រធានមន្ទីរជំនាញរាជធានី ខេត្ត
# នៃក្រសួងទាំង១០ ដែលអនុវត្តសាកល្បង
# ថវិកាកម្មវិធីពេញលេញក្នុងឆ្នាំ២០១៥

លេខ: ១០២៦៦ សហវ

ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០២៦៦...សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤

០៨ មករា ២០១៥
ម៉ោង

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សំណើប្រគល់មុខងារជាអាណាប័កផ្ទេរសិទ្ធិ ជូនប្រធានមន្ទីរជំនាញរាជធានី-ខេត្ត នៃក្រសួងទាំង១០ ដែលអនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញ ក្នុងឆ្នាំ២០១៥។

**យោង:** មាត្រា២៥ និងមាត្រា៦៣ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាប សម្តេចតេជោនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា ក្នុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានបួនដំណាក់កាលគឺ (១)ការបង្កើនភាពជឿទុកចិត្តលើថវិកា, (២)ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ, (៣) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤)ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម។ មកទល់នឹងពេលនេះ រាជរដ្ឋាភិបាលសម្រេចបានជោគជ័យពេញលេញដំណាក់កាលទី១ ហើយកំពុងឈានទៅសម្រេចបានជាសារវន្តដំណាក់កាលទី២ នាឆ្នាំ២០១៥ ទន្ទឹមគ្នានេះ ក៏កំពុងស្ថិតក្នុងដំណាក់កាលអន្តរកាលមួយ ដែលនឹងត្រូវឆ្ពោះទៅកាន់ដំណាក់កាលទី៣ គឺ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"។ ក្នុងន័យនេះ ក្នុងឆ្នាំ២០១៤ ថវិកាកម្មវិធីពេញលេញនឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងចំពោះក្រសួងចំនួន១០ រួមមាន÷ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងក្រសួងសាធារណការនិងដឹកជញ្ជូន។ រហូតមកដល់ពេលនេះ ក្រសួងទាំង១០នេះ បានរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនរួចហើយ និងកំពុងរៀបចំបញ្ចប់សៀវភៅថវិកាកម្មវិធី ដើម្បីត្រៀមអនុវត្តនាឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ នៅក្នុងក្របខណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសៀវភៅថវិកាកម្មវិធី មន្ទីរជំនាញរាជធានី-ខេត្ត នៃក្រសួងទាំង១០ បានរៀបចំសកម្មភាព/ចង្កោមសកម្មភាពរបស់ខ្លួន ដើម្បីអនុកម្មវិធី/កម្មវិធីពាក់ព័ន្ធ ក្នុងគោលដៅរួមចំណែកសម្រេចគោលបំណងគោលនយោបាយរបស់សាមីក្រសួងនីមួយៗ។

ដើម្បីឱ្យថវិកាកម្មវិធីអាចអនុវត្តបាន ដោយអនុលោមតាមមាត្រា២៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកំណត់អំពីគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី។ នៅពេលនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំរួចហើយ នូវសេចក្តីព្រាង "*គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី*" ។

គោលការណ៍ណែនាំនេះ មិនត្រឹមតែជាមគ្គុទ្ទេសក៍គ្រប់ជ្រុងជ្រោយសម្រាប់ក្រសួង ស្ថាប័នថវិកាកម្មវិធីអនុវត្តប៉ុណ្ណោះទេ ថែមទាំងមានទិសដៅសម្រួលនីតិវិធី និងកាត់បន្ថយការិយាធិបតេយ្យនៅក្នុងការអនុវត្តចំណាយថវិកាថែមទៀតផង ជាពិសេស តាមរយៈការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវជាបណ្ដើរៗក្នុងការចាត់ចែងនិងគ្រប់គ្រងថវិកា ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្រសួង ស្ថាប័ន និងនៅផ្ទៃក្នុងក្រសួង ស្ថាប័ន គឺពីអង្គភាពហិរញ្ញវត្ថុ ទៅអង្គភាពថវិកាដោយរួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត ដែលជាតួអង្គអនុវត្តសកម្មភាពការងារផ្ទាល់របស់ក្រសួង ស្ថាប័ន។

ស្របតាមមាត្រា៦៣ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រដ្ឋមន្ត្រីនៃក្រសួងទាំង១០ ដែលជាអាណាប័កដើមខ្សែ អាចប្រគល់មុខងារជាអាណាប័កផ្ទេរសិទ្ធិ ជូនដល់អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបានាកិច្ចប្រតិបត្តិការ ហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជូនដល់ប្រធានមន្ទីរជំនាញរាជធានី-ខេត្តសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិការបស់ខ្លួន។ ម្យ៉ាងវិញទៀត នៅក្នុងដំណាក់កាលនេះ រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ចាប់ផ្ដើមអនុវត្តថវិកាកម្មវិធីនៅឡើយ ចំណែកឯមន្ទីរជំនាញរាជធានី-ខេត្តវិញ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងការចូលរួមសម្រេចគោលដៅសូចនាករសមិទ្ធកម្ម ដែលត្រូវបានកំណត់នៅក្នុងអនុកម្មវិធី/ កម្មវិធីពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់សាមីក្រសួងនីមួយៗ។ នៅក្នុងន័យនេះ *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគាំទ្រដល់ការប្រគល់មុខងារជាអាណាប័កផ្ទេរសិទ្ធិជូនដល់មន្ទីរជំនាញនៃក្រសួងទាំង១០ ដែលត្រូវអនុវត្តសាកល្បងថវិកាកម្មវិធី [illegible] ថវិកាកម្មវិធី។* ទន្ទឹមនឹងនេះ ការប្រគល់មុខងារនេះ គួរត្រូវបានចាត់ទុកថា ជាជំហានចាប់ផ្ដើមយ៉ាងសំខាន់ នៅក្នុងដំណើរការនៃការផ្ទេរសិទ្ធិអំណាច ធនធាន និងការទទួលខុសត្រូវពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព ទៅដល់អង្គភាពជំនាញនៅថ្នាក់រាជធានី-ខេត្ត។

បន្ទាប់ពីបានទទួលការសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្ដេចតេជោនាយករដ្ឋមន្ត្រី លើការប្រគល់មុខងារនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំបញ្ចប់គោលការណ៍ណែនាំស្ដីពីការអនុវត្តថវិកាកម្មវិធី ដូចមានបញ្ញត្តិក្នុងមាត្រា២៥ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីដាក់ឱ្យអនុវត្តចាប់ដើមខែមករា ឆ្នាំ២០១៥ ខាងមុខនេះ។

*សូមគោរពជូនភ្ជាប់នូវសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធីនិងសេចក្ដីព្រាងប្រកាសដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។*

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម សម្ដេចតេជោនាយករដ្ឋមន្ត្រី មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ព្រមទាំងសូមមេត្តាផ្ដល់ការណែនាំជាយថាហេតុ។

សូមសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

31-12-14

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងថវិកាកម្មវិធី....................

លេខ.........................

ប្រកាស
ស្តីពី
ការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរឥណទានថវិកា

រដ្ឋមន្ត្រី.........................

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៥អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ..........សហវ.ប្រក ចុះថ្ងៃទី...... ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ..........សហវ.ប្រក ចុះថ្ងៃទី.......ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមគណនីនិងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ..........សហវ.ប្រក ចុះថ្ងៃទី.......ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

## សម្រេច

**ប្រការ១.-**

ប្រធានមន្ទីរជំនាញរាជធានី/ខេត្ត...............................ត្រូវទទួលបន្ទុកជាអាណាប័កផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងឥណទានថវិកាបេស់មន្ទីរ...........................................។

**ប្រការ២.-**

ឥណទានថវិការបស់មន្ទីរ.................................រាជធានី/ខេត្ត..............................សម្រាប់ចំណាយក្នុងឆ្នាំ២០១៩ មានទឹកប្រាក់សរុបចំនួន....................................................................រៀល "ទឹកប្រាក់សរសេរជាអក្សរ" ត្រូវបានបែងចែកតាមក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដូចមានក្នុងសៀវភៅថវិកាកម្មវិធីដែលភ្ជាប់នឹងប្រកាសនេះ។

**ប្រការ៣.-**

អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត........................................និងប្រធានមន្ទីរ.........................ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី.............ខែ.................ឆ្នាំ២០១៩

រដ្ឋមន្ត្រី

ក្រសួង.................................

**ចម្លងជូន**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ៣
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ..........
- រតនាគាររាជធានី/ខេត្ត...................
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ